**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមប្រកាសគាំទ្រពេញទំហឹងចំពោះការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ តាមសាលក្រមព្រហ្មទណ្ឌលេខ **១៨២ “ម”** ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ដែលបានផ្តន្ទាទោសជនជាប់ចោទ **កឹម សុខា** ដាក់ពន្ធនាគារកំណត់រយៈពេល ២៧ឆ្នាំ និងទោសបន្ថែមតាមការកំណត់នៃច្បាប់ ពីបទ **“សន្ទិដ្ឋិភាពជាមួយបរទេសឬបទឃុបឃិតត្រូវរ៉ូវគ្នាជាមួយបរទេស”**។

ការឃុបឃិតត្រូវរ៉ូវគ្នាជាមួយរដ្ឋបរទេស ឬភ្នាក់ងារបរទេស ក្នុងគោលបំណងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដោយប្រើប្រាស់កម្លាំងមហាជន ឬធ្វើបដិវត្តពណ៌ គឺជាអំពើក្បត់ជាតិដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិភាពប្រទេស សន្តិសុខជាតិ ស្ថិរភាពសង្គម និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋ។

យើងខ្ញុំទាំងអស់គ្នា សំណូមពរដល់ស្ថាប័នមានសមត្ថកិច្ចអនុវត្តម៉ឺងម៉ាត់សាលក្រមរបស់តុលាការ ដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា ព្រមទាំងរក្សានូវសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម និងសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជាជានិច្ចនិរន្តរ៍។

ថ្ងៃសៅរ៍ ១៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com